ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ :..១.៧.២.៤..រកម-ឧក

អនុក្រឹត្យ

ស្តីពី

ការបង្កើតគណៈកម្មាធិការគោលនយោបាយសារពើពន្ធ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០៤/០០២ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចសារនៃការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជាក្នុងអង្គការពាណិជ្ជកម្មពិភពលោក
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៩/០១៧ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០៤ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួម ក្នុងអនុសញ្ញាស្តីពីការបង្កើតក្រុមប្រឹក្សាសហប្រតិបត្តិការគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៣/០០១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាអន្តរជាតិស្តីពីការធ្វើឱ្យស៊ីចង្វាក់គ្នា នៃការ[illegible]

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រីប្រចាំការ និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

សម្រេច

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

មាត្រា១.-

ត្រូវបានបង្កើតគណៈកម្មាធិការគោលនយោបាយសារពើពន្ធ ដែលសរសេរជាអក្សរកាត់ថា "គ.គ.ស." ដើម្បីពិនិត្យ សម្របសម្រួល និងលើកសំណើកែសម្រួលគោលនយោបាយសារពើពន្ធ ដោយឈរលើគោលការណ៍សមធម៌, សាមញ្ញភាព, តម្លាភាព, គណនេយ្យភាព និងប្រសិទ្ធភាព។

ជំពូកទី២

សមាសភាពនិងបេសកម្ម

មាត្រា២.-

គ.គ.ស.មានសមាសភាព ដូចខាងក្រោម÷

១.រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	ប្រធាន
២.រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	អនុប្រធានប្រចាំការ
៣. តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
៤. តំណាងក្រសួងមហាផ្ទៃ	សមាជិក
៥. តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
៦. តំណាងក្រសួងពាណិជ្ជកម្ម	សមាជិក
៧. តំណាងក្រសួងឧស្សាហកម្មនិងសិប្បកម្ម	សមាជិក
៨. តំណាងក្រសួងរ៉ែនិងថាមពល	សមាជិក
៩. តំណាងក្រសួងបរិស្ថាន	សមាជិក
១០. តំណាងក្រសួងសុខាភិបាល	សមាជិក
១១. តំណាងក្រសួងទេសចរណ៍	សមាជិក
១២. តំណាងធនាគារជាតិនៃកម្ពុជា	សមាជិក
១៣. តំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ	សមាជិក
១៤. តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	សមាជិក
១៥.អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ	សមាជិក

១៦.អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

១៧.អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក។

សមាសភាពជាក់ស្តែងនៃ គ.គ.ឲ. ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មាត្រា៣.-

គ.គ.ឲ. មានភារកិច្ច ដូចតទៅ÷

- ពិនិត្យនិងអនុម័តលើសេចក្តីព្រាងគោលនយោបាយសារពើពន្ធ ព្រមទាំងផែនការយុទ្ធសាស្ត្រនិងផែនការសកម្មភាពសម្រាប់អនុវត្តគោលនយោបាយខាងដើម
- ពិនិត្យ វាយតម្លៃ និងលើកសំណើកែសម្រួលមូលដ្ឋាននិងអត្រាពន្ធអាករគ្រប់ប្រភេទ ដោយអនុលោមតាមគោលនយោបាយនិងផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ព្រមទាំងកិច្ចព្រមព្រៀងនិងបទដ្ឋានគតិយុត្តអន្តរជាតិផ្សេងទៀតពាក់ព័ន្ធវិស័យសារពើពន្ធ និងពាណិជ្ជកម្មអន្តរជាតិ ដើម្បីធានាបាននូវបរិស្ថានធុរកិច្ចប្រកបដោយសមធម៌និងកិច្ចសម្រួលពាណិជ្ជកម្ម និងប្រសិទ្ធភាពនៃការកៀរគរចំណូលសារពើពន្ធ
- ពិនិត្យនិងផ្តល់អនុសាសន៍លើគោលនយោបាយពាក់ព័ន្ធសារពើពន្ធ តាមការកំណត់របស់រាជរដ្ឋាភិបាល។

ចំពោះបញ្ហាពាក់ព័ន្ធវិស័យសារពើពន្ធដែលមានវេទយិតភាពខ្ពស់ គ.គ.ឲ. អាចស្នើសុំទៅគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យនិងសម្រេច។

ជំពូកទី៣

ដំណើរការការងារ

មាត្រា៤.-

សមាសភាពនៃ គ.គ.ឲ. ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន។

ប្រធាន គ.គ.ឲ. ត្រូវដឹកនាំអង្គប្រជុំ។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានប្រចាំការត្រូវដឹកនាំអង្គប្រជុំ ជំនួស។

ប្រធាន គ.គ.ឲ. អាចអញ្ជើញអ្នកជំនាញ និងតំណាងក្រសួង ស្ថាប័នដែលមិនមែនជាសមាជិកនៃ គ.គ.ឲ. ចូលរួមប្រជុំតាមការចាំបាច់។

គ.គ.ឲ. មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ដំណើរការការងាររបស់ខ្លួន។

មាត្រា៥.-

គ.គ.ឲ. មានលេខាធិការដ្ឋានមួយជាសេនាធិការ ក្នុងការបំពេញមុខងាររបស់ខ្លួន។

អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញមុខងារជាលេខាធិការដ្ឋាន គ.គ.ឲ. ។

មាត្រា៦.-

លេខាធិការដ្ឋាន គ.គ.ឲ. មានភារកិច្ច ដូចតទៅ÷

- សម្របសម្រួលការងាររដ្ឋបាល និងធានាកិច្ចដំណើរការរបស់ គ.គ.ឲ.
- សិក្សាស្រាវជ្រាវអំពីបទដ្ឋានគតិយុត្តពាក់ព័ន្ធគោលនយោបាយសារពើពន្ធ ព្រមទាំងនិន្នាការវិវឌ្ឍន៍នៃគោលនយោបាយសារពើពន្ធជាតិនិងអន្តរជាតិ និងពាណិជ្ជកម្មអន្តរជាតិ ដើម្បីធ្វើជាមូលដ្ឋានក្នុងការលើកសំណើកែលម្អគោលនយោបាយសារពើពន្ធ

- រៀបចំនិងលើកសំណើកែលម្អគោលនយោបាយនិងយុទ្ធសាស្ត្រពាក់ព័ន្ធវិស័យសារពើពន្ធ
- បូកសរុបនិងវាយតម្លៃលើការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រពាក់ព័ន្ធវិស័យសារពើពន្ធ
- បំពេញការកិច្ចផ្សេងទៀតតាមការកំណត់របស់ប្រធាន គ.គ.ព.។

ជំពូកទី៤

អវសានប្បញ្ញត្តិ

មាត្រា៧.-

បទបញ្ជាត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៨.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០១៥

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

កន្លែងទទួលៈ
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- អ្នកចមាត្រា៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ